# សេចក្តីប្រកាសនៃការចុះឈ្មោះ/ព័ត៌មាននៃកម្មវិធី/ការណាត់ពេលជួបធ្វើការណែនាំនៃកម្មវិធី CAL-LEARN

| | |
|---|---|
| កាលបរិច្ឆេទ : | |
| ឈ្មោះសំណុំរឿង : | |
| លេខសំណុំរឿង : | |
| លេខទូរស័ព្ទ : | |
| ឈ្មោះអ្នកចុះឈ្មោះ : | |

## ការពន្យល់អំពីកម្មវិធី CAL-LEARN

កម្មវិធីCal-Learn ត្រូវបានរៀបចំឡើងដើម្បីជួយជម្រុញនិងជួយចំពោះមាតាបិតាដែលមានវ័យជំទង់ឱ្យនៅសិក្សា ឬវិលត្រឡប់ទៅកាន់សាលារៀនវិញ ។

### អ្នកចុះឈ្មោះ

គេបានចុះឈ្មោះឱ្យលោកអ្នកចូលរួមជាមួយកម្មវិធីCal-Learn ។ លោកអ្នកត្រូវតែចូលរួមជាមួយកម្មវិធី Cal-Learn លុះត្រាតែលោកអ្នកត្រូវបានលើកលែង ។

លោកអ្នកត្រូវតែចូលរួមជាមួយកម្មវិធី Cal-Learn បើសិនជាលោកអ្នកមានផ្ទៃពោះឬជាឪពុកម្តាយដែលជាអ្នកអាណាព្យាបាលដែលមានអាយុតិចជាង១៩ឆ្នាំ ហើយមិនមានសញ្ញាបត្រមធ្យមសិក្សា ឬសញ្ញាបត្រដែលស្មើគ្នានេះ ។

បើសិនជាលោកអ្នកចូលអាយុ១៩ឆ្នាំនៅក្នុងពេលដែលលោកអ្នកនៅក្នុងកម្មវិធី Cal-Learn ហើយដែលមិនបានបញ្ចប់សាលាមធ្យមសិក្សា ឬសាលាដូចគ្នានេះ លោកអ្នកអាចបន្តចូលរួមជាមួយកម្មវិធីនេះរហូតទាល់តែលោកអ្នកចូលអាយុ២០ឆ្នាំ ។

### តើកម្មវិធី CAL-LEARN មានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?

- កម្មវិធី Cal-Learn ជួយលើកទឹកចិត្តក្មេងជំទង់ដែលទទួលជំនួយពីកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (CalWORKs) ដែលមានផ្ទៃពោះ ឬដែលជាឪពុកម្តាយរួចហើយឱ្យនៅសិក្សា ឬវិលត្រឡប់ទៅកាន់សាលារៀនវិញ ។ អ្នកចូលរួមអាចទទួលប្រាក់ជំនួយសំរាប់ការអនុវត្តតាមការតម្រូវរបស់កម្មវិធី ។
- អ្នកចូលរួមជាមួយកម្មវិធីCal-Learn នឹងទទួលកិច្ចជួយផ្នែករៀបចំសំណុំរឿង ហើយនិងជំនួយសំរាប់បង់ថ្លៃថែរក្សាក្មេងនិងយានដឹកនាំ ។
- អ្នករៀបចំសំណុំរឿងរបស់លោកអ្នកនឹង :
  - ជួយចំពោះលោកអ្នកផ្នែកថែរក្សាសុខភាព និងកិច្ចជួយដែលបានត្រូវការដែលមានផ្តល់ឱ្យនៅក្នុងសហគមន៍ ។
  - ជំរាបឱ្យលោកអ្នកបានដឹងអំពីប្រភេទផ្សេងៗនៃការថែរក្សាក្មេង និងទីណាដែលលោកអ្នកអាចរកបានកិច្ចថែរក្សាក្មេង ។
  - ធ្វើឱ្យជាក់ថាលោកអ្នកបានយល់អំពីការតម្រូវនៃកម្មវិធី ហើយនិងអ្វីអាចកើតមានឡើងបើសិនជាលោកអ្នកមិនធ្វើតាមការតម្រូវទាំងនេះ ។
  - ជួយលោកអ្នកបង្កើតជាគ្រោងការសិក្សាអប់រំមួយ ។
  - តាមមើលការរីកចំរើនរបស់លោកអ្នក និងជួយលោកអ្នកធ្វើការកែប្រែជាចាំបាច់ណាមួយទៅលើកម្មវិធីសាលារៀនរបស់លោកអ្នក ។

ជំហានជាបន្ទាប់សំរាប់លោកអ្នកគឺការចូលរួមជាមួយការណែនាំនៃកម្មវិធី Cal-Learn ។

លោកអ្នកត្រូវបានណាត់ពេលឱ្យចូលរួមជាមួយការណែនាំនេះនៅ________________វេលាម៉ោង ____________________ នៅ ____________________________________

_____________________________________________________________។

បើសិនជាលោកអ្នកមិនអាចរក្សាការណាត់ជួបនេះបានទេ សូមទូរស័ព្ទទៅអ្នកចាត់ចែងសំណុំរឿងCal-Learn របស់លោកអ្នក: ________________________ នៅ________________ នៅឬមុន________________________ ដើម្បីធ្វើការណាត់ជួបដទៃទៀត ។

សេចក្តីប្រកាសនេះមិនមែនសំរាប់ជំរាបអំពីការតម្រូវនៃកម្មវិធីឡើយ ។ ការតម្រូវនៃកម្មវិធី Cal-Learn នឹងត្រូវបានផ្តល់ជូនលោកអ្នកនៅក្នុងពេលជួបណែនាំបង្ហាញ ។

**លោកអ្នកត្រូវតែអញ្ជើញទៅកាន់ពេលណែនាំបង្ហាញ ទោះបីជាលោកអ្នកគិតថាខ្លួនប្រហែលជាត្រូវបានលើកលែង ឬត្រូវបានពន្យារពេលឱ្យក៏ដោយ ។**

បើសិនជាលោកអ្នកគិតថាសកម្មភាពនេះខុស លោកអ្នកអាចស្នើសុំសេចក្តីបំភ្លឺមួយ ។ ព័ត៌មានអំពីសិទ្ធិស្នើសុំសេចក្តីបំភ្លឺនៃកម្មវិធី Cal-Learn នៅខាងខ្នងនៃសំណៅនេះមានជំរាបលោកអ្នកអំពីរបៀប ។

លោកអ្នកក៏ អាចទូរស័ព្ទទៅអ្នកកាន់សំណុំរឿងនៃកម្មវិធី Cal-Learn របស់លោកអ្នកផងដែរ បើសិនជាលោកអ្នកគិតថាសេចក្តីប្រកាសនេះខុស ។